ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# អនាគតខ្ញុំ

(សៀវភៅសិស្ស)



## បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
## គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**គណៈកម្មការអភិវឌ្ឍសៀវភៅ**

**"អនាគតខ្ញុំ"**

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោកស្រី អេលិន ជោច (Eileen St. George)

២. លោក ចាន់ ណារិន

៣. លោក សៅ ប៊ុនធឿន

**គណៈកម្មការកែសម្រួល**

១. លោក ឃុំ វណ្ណធន

២. លោកស្រី មុំ មេត

៣. លោក ប៉ុល សុរិទ្ធ

**គណៈកម្មការពិនិត្យ**

១. លោក ព្រុំ វិបុល

២. លោក មាស ជុតិមា

៣. លោក ហួត នរៈ

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិចដើម្បីអភិវឌ្ឍអន្តរជាតិ (USAID)

សហការរៀបចំដោយ

អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា

ទំព័រ

អារម្ភកថា ........................................................................ ០១

មេរៀនទី ១ : ការកំណត់គោលដៅ ................................................................ ០២

មេរៀនទី ២ : គោលដៅ និង អនាគតអ្នក ,,,.......,,,,,,,,,,,,,,,,,,,,,.,,,,,,,,,,,,,,,,,,,,, ០៩

មេរៀនទី ៣ : ការធ្វើផែនទីកំណត់ទីតាំងមុខរបរ ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,.......,,,,,,,,,,,,, ១១

មេរៀនទី ៤ : ការចាប់អារម្មណ៍លើមុខរបរ និង ការស្រាវជ្រាវ ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ១៣

មេរៀនទី ៥ : ការធ្វើសម្ភាសពីមុខរបរ ,,,,,,,,,...............................,,,,,,,,,,,,,,,,,,,,,,,,,,,,,, ១៦

មេរៀនទី ៦ : ការធ្វើផែនការសម្រាប់អនាគតអ្នក,,,,,........,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ១៨

មេរៀនទី ៧ : ការធ្វើសេចក្តីសម្រេចចិត្ត ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ២១

មេរៀនទី ៨ : អ្នកធ្វើការសម្រេចចិត្តដែលឈ្លាសវៃ ,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,,, ៣០

ការសង្ខេបពីខ្លឹមសារឯកសារស្តីពី "**អនាគតខ្ញុំ** " ............................................. ៣១

## អារម្ភកថា

ឯកសារ " **អនាគតខ្ញុំ** " មានគោលបំណងជួយអ្នកសិក្សាទាំងអស់ឱ្យទទួលបានចំណេះដឹង និង ជំនាញ ដែលអាចពង្រីកគោលគំនិតអំពីលទ្ធភាពនៃការជ្រើសរើសមុខរបរនាពេលអនាគត ។ ទោះបីជាមានប្រភេទ មុខរបរ ដែលផ្តល់តាមរយៈនិយោជិក ឬ មុខរបរដែលបង្កើតឡើងដោយខ្លួនឯងក៏ដោយ ។ ការសិក្សាបន្ថែមទៀតពីជំនាញដែល មានស្រាប់ ពីតម្រូវការការអប់រំ ចំណេះដឹង និង ជំនាញផ្សេងៗទៀត សម្រាប់ធ្វើផែនការ ស្វែងរកការងារ និងធ្វើការ សម្រេចចិត្ត ។ សព្វថ្ងៃនេះ យុវជនជាច្រើនមិនបានកំណត់ពីវិថីនៃអនាគតរបស់ពួកគេទេ ដោយការគាប់ជួនសុទ្ធសាធ គឺមិនមែនដោយការតាំងចិត្ត ដែលគេស្វែងរកពិតប្រាកដនោះទេ ។ ការជួយពួកគេក្នុងការស្រាវជ្រាវ អំពីជំនាញផ្សេងៗ ការកំណត់ផែនការសកម្មភាព និង ការសម្រេចចិត្តរើសយកជំនាញអ្វីមួយនោះ ជាកត្តាជំរុញឱ្យពួកគេឆ្ពោះទៅរក ជំនាញជាក់លាក់ អាចធ្វើឱ្យគេមានការជឿជាក់លើខ្លួនឯង និង មានភាពក្លាហានក្នុងការស្វែងរកមុខរបរ ដើម្បីកសាង អនាគតរបស់ខ្លួន ។ យើងសង្ឃឹមថាយុវជននាសម័យនេះ អាចធ្វើការជ្រើសរើសមុខរបរអ្វីមួយ ដោយមានព័ត៌មាន គ្រប់គ្រាន់ ដែលខ្លួនអាចទទួលយកបាន ។

## មេរៀនទី១ : ការកំណត់គោលដៅ

**✡ លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

- ប្រាប់ពីអត្ថន័យនៃ ពាក្យ " គោលដៅ "
- កំណត់គោលដៅសម្រាប់អនាគតខ្លួនដោយមានភាពប្រាកដនិយម ។

| សកម្មភាពទី ១ : តើគោលដៅជាអ្វី? | ◷ ១៥ នាទី |
|---|---|

១. តើអ្នកអាចឱ្យនិយមន័យនៃពាក្យ " គោលដៅ " បានដែរឬទេ? ចូរលើកឧទាហរណ៍បញ្ជាក់ ។

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

២. តើហេតុអ្វីបានជាការកំណត់គោលដៅមានសារៈសំខាន់?

_______________________________________________

_______________________________________________

_______________________________________________

| សកម្មភាពទី២ : ធាតុទាំង ៤ ក្នុងការសរសេរគោលដៅ |
|---|

១. **អ្នកណា?** ប្រសិនបើខ្លួនយើងផ្ទាល់ ជាអ្នកសរសេរគោលដៅនោះ យើងត្រូវសរសេរថា " ខ្ញុំ "

២. **អ្វី?** ( តើអ្វីដែលអ្នកចង់សម្រេចឱ្យបាន? ឧ. ពាណិជ្ជករ មេធាវី អ្នកបច្ចេកទេសគ្រឿងយន្ត ...)

៣. **នៅទីណា?** តើនៅទីណាដែលអ្នកចង់ទៅដល់ដើម្បីសម្រេចគោលដៅនេះ?

៤. **ពេលណា?** តើអ្នកសង្ឃឹមថាអ្នកអាចសម្រេចគោលដៅនេះនៅពេលណា?

សកម្មភាពទី៣ ៖ ឧទាហរណ៍ពីការប្រើធាតុទាំង ៤ ក្នុងការសរសេរគោលដៅ

នេះជាគំរូនៃការបង្កើតគោលដៅមួយចំនួន ។ ចូរកំណត់ពីលក្ខណៈខុសគ្នានៃធាតុទាំង ៤ ដែលប្រើសម្រាប់គោលដៅនីមួយៗ ។

១. **នៅឆ្នាំនេះ** ខ្ញុំនឹងបង្កើនសមត្ថភាពផ្នែកគណិតវិទ្យាឱ្យកាន់តែល្អប្រសើរ ។

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

២. ខ្ញុំនឹងចូលរៀននៅសាកលវិទ្យាល័យទីក្រុងភ្នំពេញ ដើម្បីសិក្សាផ្នែកជំនួញនៅឆ្នាំក្រោយមួយទៀត ។

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

៣. ខ្ញុំនឹងរៀនភាសាអង់គ្លេសឱ្យមានចំណេះគ្រប់គ្រាន់ ដែលអាចធ្វើការបាននៅកន្លែងដែលមានជនបរទេស នៅទីក្រុងណាមួយ ឬ ទីប្រជុំជន ពេលខ្ញុំបញ្ចប់ការសិក្សានៅវិទ្យាល័យ ។

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

៤. ខ្ញុំ នឹងធ្វើការងារដើម្បីសន្សំប្រាក់ទិញម៉ូតូមួយ សម្រាប់ប្រកបមុខរបររត់ម៉ូតូឌុប នៅទីប្រជុំជនក្នុងកំឡុង ៦ ខែខាងមុខ ។

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

៥. ឆ្នាំក្រោយ ខ្ញុំនឹងមានរាងកាយមាំមួនដើម្បីចូលរួមការប្រកួតរត់ពាក់កណ្តាលម៉ារ៉ាតុននៅខេត្តសៀមរាប ។

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

## ការកំណត់គោលដៅជាមួយធាតុទាំង៤

ចូរបង្កើតគោលដៅ ២ ។ អ្នកត្រូវប្រាកដថា ប្រយោគគោលដៅដែលអ្នកបង្កើតត្រូវមានធាតុទាំង៤ ។

☞ គោលដៅទី១ :

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

☞ ហេតុអ្វីបានជាគោលដៅនេះមានសារៈសំខាន់ចំពោះអ្នក?

☝ គោលដៅទី២ ៖

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

☝ ហេតុអ្វីបានជាគោលដៅនេះមានសារៈសំខាន់ចំពោះអ្នក?

## សកម្មភាពទី៤ ៖ ការប្រើធាតុទាំង ៤ +២ ទៀត ក្នុងការធ្វើផែនការដើម្បីសម្រេចគោលដៅ

ការសរសេររៀបរាប់ពីគោលដៅជាក់លាក់មួយ គឺការធ្វើផែនការដើម្បីឈានទៅដល់គោលដៅនោះ។ ម្យ៉ាងទៀត នៅពេលធ្វើផែនការនេះ យើងត្រូវផ្តោតការយកចិត្តទុកដាក់ និង មានគោលបំណងជាក់លាក់។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ នៅពេលអនុវត្តផែនការ នៅតែមានការកែសម្រួលសកម្មភាពខ្លះៗនៃផែនការ (អាស្រ័យទៅតាមការវិវឌ្ឍធនធាន ស្ថានភាព និង ព្រឹត្តិការណ៍)។

**ការប្រើធាតុ៤ +២ ក្នុងការធ្វើផែនការដើម្បីសម្រេចគោលដៅ**

១. ៤+១ " **ធ្វើដូចម្តេច?** " តើអ្នកអាចសម្រេចគោលដៅបានយ៉ាងដូចម្តេច?

- o **សកម្មភាព ៖** តើមានសកម្មភាពអ្វីខ្លះដែលត្រូវការចាំបាច់ដើម្បីឈានទៅដល់គោលដៅរបស់អ្នក?
- o **សេចក្តីត្រូវការ ៖** ដើម្បីសម្រេចគោលដៅនេះ តើអ្នកត្រូវការអ្វីខ្លះ ?(ការអប់រំ បទពិសោធន៍ ធនធាន បណ្តាញគាំទ្រ ...)

២. ៤+២ "**ភាពអាចធ្វើបាន**" តើគោលដៅនេះមានភាពប្រាកដជាក់លាក់ និង អាចសម្រេចទៅបានដែរឬទេ?

**សកម្មភាពទី៥ : ការប្រើធាតុទាំង ៤+១ ក្នុងការធ្វើផែនការគោលដៅ : " ធ្វើដូចម្តេច "**

១. ប្រសិនបើឧទាហរណ៍ខាងក្រោមនេះជាគោលដៅរបស់អ្នក តើអ្នកនឹងត្រូវសរសេរអ្វីខ្លះក្នុងធាតុ " **ធ្វើដូចម្តេច** " ដើម្បីឱ្យសម្រេចគោលដៅ?

" នៅឆ្នាំនេះ ខ្ញុំនឹងបង្កើនសមត្ថភាពផ្នែកគណិតវិទ្យាខ្ញុំ ពីចំណុចដែលខ្ញុំមិនយល់សោះកាលពីពេលកន្លងមកឱ្យបានល្អប្រសើរនៅចុងឆ្នាំនេះ ។ "

តើអ្នកនឹងធ្វើយ៉ាងដូចម្តេចដើម្បីឱ្យសម្រេចគោលដៅនេះ?

________________________________________

________________________________________

________________________________________

២. ប្រសិនបើឧទាហរណ៍នេះជាគោលដៅរបស់អ្នក តើមានជំហាន ឬ សកម្មភាពអ្វីខ្លះដែលអ្នកអាចប្រើជាមធ្យោបាយដើម្បីឱ្យសម្រេចគោលដៅនេះ?

ជំហាន ឬ សកម្មភាព :

________________________________________

________________________________________

________________________________________

៣. តើតម្រូវការចាំបាច់អ្វីខ្លះ ដែលអ្នកអាចត្រូវការដើម្បីអនុវត្តជំហាន និង សកម្មភាពទាំងនេះ?( ធនធាន ការអប់រំ បទពិសោធន៍ ការគាំទ្រ....)

ជំហាន ឬ សកម្មភាព :

________________________________________

________________________________________

________________________________________

# សៀវភៅសិស្ស

៤. សម្រាប់គោលដៅផ្ទាល់ខ្លួន ២ របស់អ្នកដែលមាននៅទំព័រទី ៤ និង ៥ ចូរសរសេរធាតុ ៤+១ " **ធ្វើដូចម្តេច?** " នៅក្នុងជំហាន និង តម្រូវការខាងក្រោម។ ប្រសិនបើមិនមានកន្លែងគ្រប់គ្រាន់ទេ សូមសរសេរនៅក្នុងសៀវភៅកត់ត្រាមេរៀនរបស់អ្នក។

☞ គោលដៅទី១ :

| |
|---|
| **ជំហាន** = |
| |
| |
| |
| |
| **តម្រូវការ** = |
| |
| |
| |
| |

☞ គោលដៅទី២ :

| |
|---|
| **ជំហាន** = |
| |
| |
| |
| |
| **តម្រូវការ** = |
| |
| |
| |
| |

**កិច្ចការផ្ទះ**

១. ចូរសរសេរបំពេញគោលដៅផ្ទាល់ខ្លួន ២។ គោលដៅទាំង២នេះគួរតែជាអ្វីដែលអ្នកសង្ឃឹមថាអាចសម្រេចបាននៅខែក្រោយ ឬ ឆ្នាំក្រោយ។ គោលដៅទាំងនេះអាចជាផ្នែកផ្សេងៗនៃជីវិតរស់នៅរបស់អ្នក ដូចជា ការអប់រំ អាជីពការងារ គ្រួសារ ទំនាក់ទំនងសង្គម ចំណង់ចំណូលចិត្ត ការអភិវឌ្ឍបុគ្គល ឬអ្វីផ្សេងទៀត។

២. ចំពោះការសរសេរគោលដៅរបស់អ្នក គួរដាក់បញ្ចូលនូវធាតុ ៤+១ ។

## មេរៀនទី២ : គោលដៅ និង អនាគតអ្នក

☼ **លទ្ធផលរំពឹងទុកពេលរៀនមេរៀនចេះចប់សិស្សនឹងអាច :**

- កំណត់អត្ថន័យ និង យល់ពីគោលដៅ
- កំណត់គោលដៅសម្រាប់អនាគតដែលមានទាំងភាពជាក់លាក់នឹងអាចសម្រេចបាន
- ទទួលបានបទពិសោធន៍ និងយល់ពីបញ្ហាប្រឈមនៅក្នុងការកំណត់ និងការធ្វើឱ្យសម្រេចនូវគោលដៅ ។

### ការកំណត់គោលដៅដែលអាចសម្រេចបាន

នៅពេលបង្កើតគោលដៅ ចូរអ្នកចាំឱ្យច្បាស់ថា អ្នកមិនត្រូវស្រមើស្រមៃតាមការគិតរវើរវាយនោះទេ គឺយើងត្រូវលើកឡើងពីគោលដៅដែលអាចកើតមានប្រាកដ ដែលជាពន្លឺនៃក្ដីសង្ឃឹម គោលដៅត្រូវកំណត់ទៅតាមលទ្ធភាពបុគ្គលម្នាក់ៗ សេចក្ដីព្យាយាម (សេចក្ដីសម្រេចចិត្តគង់បានសម្រេច) ។ ប្រសិនបើអ្នកត្រូវឆ្នោត ឬ មានភ័ព្វសំណាងដែលហួសពីការត្រួតត្រារបស់អ្នក នោះវាមិនមែនជាគោលដៅទេ ។

១. តើព័ត៌មានសំខាន់ៗអ្វីខ្លះ ដែលអាចធ្វើឱ្យគោលដៅនោះអាចអនុវត្តបាន អាចសម្រេចបាន និង មានភាពប្រាកដជាក់លាក់?"

________________________________________

________________________________________

________________________________________

២. ចូរសង្កេតមើលគោលដៅផ្ទាល់ខ្លួន ២ ដែលអ្នកបានធ្វើសម្រាប់កិច្ចការផ្ទះនោះ រួចបំពេញធាតុចុងក្រោយ "**+២**" ដែលបញ្ជាក់ពីភាពអាចធ្វើបាន ។

៣. នៅពេលអ្នកធ្វើកិច្ចការនេះចប់ ចូរសួរខ្លួនឯងនូវសំណួរមួយចុងក្រោយថា " តើគោលដៅនោះអាចធ្វើបាន អាចសម្រេចបាន និង មានភាពប្រាកដជាក់លាក់ឬទេ?"

៤. ប្រសិនបើឆ្លើយថា **ទេ** នោះសូមពិនិត្យមើលឡើងវិញលើគោលដៅទាំង ២ របស់អ្នក និង ចម្លើយ "ធ្វើដូចម្ដេច?" ប៉ុន្តែបើឆ្លើយថា **ចាស/បាទ** នោះចម្លើយរបស់អ្នកគឺស្របទៅនឹងធាតុ ៤+២ ដែលធ្វើឱ្យគោលដៅរបស់អ្នកអាចធ្វើបាន ។

## ការលំបាក និង សារប្រយោជន៍ក្នុងការបង្កើតគោលដៅ

១. តើការលំបាកអ្វីខ្លះដែលអ្នកបានជួបប្រទះក្នុងការសរសេរគោលដៅ និង ការធ្វើផែនការ?

______________________________________________

______________________________________________

______________________________________________

២. តើអ្នកបានរៀនសូត្រអ្វីខ្លះដែលជាសារប្រយោជន៍សម្រាប់អ្នក និង ជាប្រយោជន៍សម្រាប់ អនាគតរបស់អ្នក?

______________________________________________

______________________________________________

______________________________________________

## មេរៀនទី ៣ : ការធ្វើផែនទីកំណត់ទីតាំងមុខរបរ

☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀនចេះចប់សិស្សនឹងអាច :

- ប្រាប់ពី មុខរបរមួយចំនួនដែលមាននៅក្នុងសហគមន៍ ស្រុក ខេត្ត ប្រទេសរបស់ពួកគេ និងប្រទេសផ្សេងៗ។
- កំណត់វិធីមួយចំនួនដើម្បីស្វែងរកមុខរបរ
- បង្ហាញពីសារៈសំខាន់នៃព័ត៌មានក្នុងការជ្រើសរើសមុខរបរ។

### ការណែនាំពីជម្រើសមុខរបរ

ការគិតពីមុខរបរដែលមាននៅក្នុងសហគមន៍វាមានសារៈសំខាន់ ពីព្រោះវាឱ្យយើងដឹងពីសក្តានុពលនៃមុខរបរដែលយើងចង់ស្វែងយល់។ ប្រសិនបើយើងមិនបានគិតពីមុខរបរជម្រើសផ្សេងៗនោះទេ យើងនឹងជួបបញ្ហាក្នុងការសម្រេចចិត្តជ្រើសរើសមុខរបរទាំងនោះ។

### ល្បែងកំណត់ឈ្មោះមុខរបរ

១. យើងនឹងគិតអំពីមុខរបរមួយចំនួនសម្រាប់ធ្វើការពិចារណា។ មុខរបរទាំងនេះអាចជាមុខរបរទូទៅ ឬមុខរបរផ្ទាល់ខ្លួន។

២. យើងនឹងលេងល្បែងដែលនឹងជួយយើងឱ្យកំណត់បានពីមុខរបរដែលយើងស្គាល់។

៣. ចូរកំណត់មុខរបរតាមបរិបទខាងក្រោម :

ក. មុខរបរដែលមានក្នុងសហគមន៍ និងនៅក្រៅសហគមន៍។

ខ. មុខរបរដែលមិនមានក្នុងសហគមន៍ ប៉ុន្តែមាននៅក្នុងស្រុកឬខេត្ត និងអាចមាននៅក្នុងស្រុកឬខេត្តផ្សេង។

គ. មុខរបរដែលមិនមាននៅក្នុងសហគមន៍ ស្រុក ឬ ខេត្ត ប៉ុន្តែមានក្នុងប្រទេសកម្ពុជា និងអាចមាននៅក្នុងប្រទេសផ្សេង។

ឃ. មុខរបរដែលមិនមាននៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ប៉ុន្តែមានក្នុងពិភពលោក។

៤. ចូរគូសតារាងដូចខាងក្រោម ៖

| | ប្រភេទមុខរបរ | | | |
|---|---|---|---|---|
| | ក | ខ | គ | ឃ |
| បញ្ជីឈ្មោះមុខរបរ | | | | |

## ការពង្រីកការយល់ដឹងអំពីមុខរបរ

នៅលើពិភពលោកយើងនេះមានមុខរបរច្រើនណាស់ ។ នៅក្នុងប្រទេសកម្ពុជាក៏មានមុខរបរច្រើនដែរ ។ មុខរបរមួយចំនួនគេមិនទាន់យល់ច្បាស់ ព្រោះគេមិនទាន់ទទួលបទពិសោធន៍ពីអ្នកមានវិជ្ជាជីវៈ ឬជាមួយនឹងមុខទំនិញឬការផ្ដល់សេវាកម្មនោះ ។

១. តើអ្នកដឹងពីមុខរបរដែលក្រុមរបស់អ្នកបានសរសេររៀបរាប់លើតារាងល្បែងមុខរបរដោយរបៀបណា?

២. តើអ្នកគិតថាធ្វើយ៉ាងណា ដើម្បីស្វែងយល់បន្ថែមទៀតពីប្រភេទផ្សេងៗនៃការងារ ឬ មុខរបរទាំងនោះ?

## មេរៀនទី៤ : ការចាប់អារម្មណ៍លើមុខរបរ និង ការស្រាវជ្រាវ

☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀនចេះចប់សិស្សនឹងអាច :

- ប្រាប់ពីអារម្មណ៍ផ្ទាល់ខ្លួន លើជំនាញ និង មុខរបរ
- ធ្វើការស្រាវជ្រាវលំអិតលើជម្រើសមុខរបរ
- បង្កើតគំនិតអំពីប្រភេទផ្សេងៗនៃជម្រើសមុខរបរ
- កំណត់គុណសម្បត្តិ និង គុណវិបត្តិ នៃ ប្រភេទផ្សេងៗនៃមុខរបរ។

### ទេពកោសល្យ ជំនាញ បទពិសោធន៍ និង ចំណាប់អារម្មណ៍របស់ខ្ញុំ

ប្រសិនបើយើងចង់ពិចារណាអំពីជម្រើសមុខរបរដែលមានលក្ខណៈប្រាកដនិយម យើងចាំបាច់ត្រូវតែប្រមូលព័ត៌មាន និងធ្វើការពិចារណាពីកត្តាផ្សេងៗដែលជះឥទ្ធិពលទៅលើដំណើរការដែលនាំយើងឆ្ពោះទៅរកមុខរបរជាក់លាក់ណាមួយ។ ថ្ងៃនេះយើងនឹងពិនិត្យមើលទៅលើកត្តាទាំងនោះ ថាតើវាមានទំនាក់ទំនងទៅនឹងគំនិតរបស់យើង អំពីមុខរបរនៅពេលអនាគតដូចម្តេចខ្លះ។

១. តើការងារអ្វីខ្លះដែលអ្នកចង់ធ្វើ?

______________________________

______________________________

______________________________

______________________________

២. តើអ្នកគិតថា អ្នកមានទេពកោសល្យ និង ជំនាញអ្វីខ្លះ?

______________________________

______________________________

______________________________

______________________________

៣. តើមុខវិជ្ជាអ្វីខ្លះដែលអ្នកចូលចិត្តសិក្សា?

៤. តើអ្នកធ្លាប់មានបទពិសោធន៍អ្វីខ្លះ?

## មុខរបរសម្រាប់ខ្ញុំ

ចូរជ្រើសរើសមុខរបរយ៉ាងតិចមួយក្នុងចំណោមមុខរបរដែលបានសរសេររៀបរាប់បញ្ជាក់ថា "អ្នកចង់ធ្វើ" អ្នកមាន " ទេពកោសល្យ និង ជំនាញ" ឬ "ចំណាប់អារម្មណ៍លើមុខវិជ្ជាសិក្សា" ។

## ការសិក្សាស្រាវជ្រាវពីជម្រើសមុខរបរ

១. ចូរធ្វើផែនការសម្ភាសន៍ជាមួយបុគ្គលដែលអាចផ្ដល់ព័ត៌មានឱ្យយើងអំពីមុខរបរណាមួយ ។

២. ចូរកំណត់មុខរបរដែលអ្នកអាចស្រាវជ្រាវព័ត៌មានបន្ថែមទៀត តាមរយៈការសម្ភាស(ជួបផ្ទាល់ ឬតាមទូរសព្ទ) ជាមួយនឹងមនុស្សដែលធ្វើការលើការងារនេះ ។

៣. នៅពេលយើងជ្រើសរើសមុខរបរណាមួយជាក់លាក់ សម្រាប់សកម្មភាពនេះ ។

៤. ចូរប្រាប់ឈ្មោះមនុស្សមួយចំនួន ដែលអ្នកអាចធ្វើទំនាក់ទំនងសម្រាប់សម្ភាស ។

៥. នេះជាបញ្ជីសំណួរសំខាន់ៗចំនួន ៩ ដែលយើងត្រូវសួរនៅពេលសម្ភាសពីមុខរបរដែលយើងបានជ្រើសរើស ។ យើងត្រូវធ្វើការកត់ត្រាពីការធ្វើសម្ភាស ហើយយើងក៏ឱ្យរៀបចំរបាយការណ៍សង្ខេបពីលទ្ធផលនៃការធ្វើសម្ភាសនីនេះ ។

១. តើបង/ពូ/មីង/អ៊ំបានធ្វើការជ្រើសរើសមុខរបរនេះយ៉ាងដូចម្ដេច?
២. សូម បង/ពូ/មីង/អ៊ំជួយពន្យល់ពីសកម្មភាពទូទៅ និង ភារកិច្ចមួយចំនួនឱ្យខ្ញុំបានដឹងផង?
៣. តើបរិយាកាសជុំវិញ ម៉ោងធ្វើការ និង តម្រូវការខាងគំនិតប្រាជ្ញា និង កាយសម្បទា មានលក្ខណៈយ៉ាងណាខ្លះសម្រាប់ការងារនេះ?
៤. តើខ្ញុំត្រូវមានការអប់រំ និងបទពិសោធន៍អ្វីខ្លះ ដើម្បីធ្វើមុខរបរនេះ?
៥. តើអ្វីដែល បង/ពូ/មីង/អ៊ំ ចូលចិត្តបំផុតសម្រាប់ការងារនេះ?
៦. តើអ្វីដែល បង/ពូ/មីង/អ៊ំមិនសូវចូលចិត្តសម្រាប់ការងារនេះ?
៧. តើ បង/ពូ/មីង/អ៊ំគិតថាការងារប្រភេទនេះជាតម្រូវការសម្រាប់អនាគតខ្ញុំដែរឬទេ?
៨. តើ បង/ពូ/មីង/អ៊ំអាចប្រាប់ខ្ញុំបានទេពីប្រាក់ខែចាប់ផ្ដើមដំបូងសម្រាប់ការងារនេះ?
៩. តើ បង/ពូ/មីង/អ៊ំមានការណែនាំអ្វីខ្លះសម្រាប់យុវជនជំនាន់ក្រោយដូចជាយើងខ្ញុំ ប្រសិនបើយើងចង់រៀបចំខ្លួនសម្រាប់ការងារមួយស្រដៀងគ្នាបែបនេះ?
១០. អ្នកអាចបន្ថែមសំណួរផ្ទាល់ខ្លួននៅខាងក្រោម បើសិនអ្នកចង់សួរ

________________________________

________________________________

**កិច្ចការផ្ទះ**

១. ចូរធ្វើការសម្ភាសជាមួយអ្នកណាម្នាក់ ដើម្បីស្វែងយល់ពីមុខរបរណាមួយ ។
២. ធ្វើការកត់ត្រាពេលធ្វើសម្ភាស ដើម្បីសរសេររបាយការណ៍ ។
៣. រៀបចំធ្វើបទបង្ហាញអំពីអ្វីដែលដែលអ្នករកឃើញ ។

កំណត់សម្គាល់

- អ្នកមានពេល ៥ នាទីសម្រាប់ធ្វើបទបង្ហាញសង្ខេប ។
- ធ្វើការអនុវត្តសាកល្បងជាមុន ហើយរក្សាទុកតែចំណុចសង្ខេបដែលសំខាន់ និង គួរចាប់អារម្មណ៍ ។

## មេរៀនទី៥ ៖ ការធ្វើសម្ភាសពីមុខរបរ

### ☼ លទ្ធផលរំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ប្រាប់ពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួន លើជំនាញ និង មុខរបរ
- ធ្វើការស្រាវជ្រាវលំអិតលើជម្រើសមុខរបរ
- បង្កើតគំនិតអំពីប្រភេទផ្សេងៗនៃជម្រើសមុខរបរ ។

### ការពិភាក្សាសង្ខេបលើលទ្ធផលនៃការធ្វើសម្ភាសមុខរបរ

១. តើអ្នកមានការភ្ញាក់ផ្អើលពីលទ្ធផលនៃមុខរបរអ្វី?

២. តើអ្នកចាប់អារម្មណ៍លើមុខរបរអ្វីខ្លាំងជាងគេ? ហេតុអ្វី?

៣. តើអ្នកបានប្រៀបធៀបពីមុខរបរដែលអ្នកបានដឹងពីមុនៗ (តើមុខរបរណាល្អជាងគេ?) សូមធ្វើការពន្យល់?

៤. តើការណែនាំអ្វីខ្លះដែលអ្នកគិតថាមានប្រយោជន៍ក្នុងការធ្វើផែនការមុខរបរសម្រាប់អនាគតអ្នក?

___

___

___

___

៥. តើមុខរបរអ្វីខ្លះដែលអ្នកចង់សិក្សាបន្ថែម ប៉ុន្តែមិនអាចរកអ្នកសម្ភាសបាន?

___

___

___

**កិច្ចការផ្ទះ**

ផ្អែកលើសំណួរដែលបានពិភាក្សាទាំង៥ ខាងលើ ចូរសរសេរនៅក្នុងសៀវភៅកត់ត្រាពីការយល់ឃើញផ្ទាល់ខ្លួនរបស់អ្នក ។

# មេរៀនទី៦ ៖ ការធ្វើផែនការសម្រាប់អនាគតអ្នក

## ☼ លទ្ធផលរំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- ប្រើប្រាស់វិធីសាស្ត្រធ្វើផែនការគោលដៅ ៤+២ ដើម្បីធ្វើការជ្រើសរើសមុខរបរមួយ
- កំណត់ផែនការជាក់លាក់សម្រាប់ធ្វើមុខរបរនោះ ។

## ពិនិត្យឡើងវិញពីវិធីសាស្ត្រធ្វើផែនការដើម្បីសំរេចគោលដៅ

១. ធាតុទាំង៤ក្នុងការសរសេរគោលដៅ

- **អ្នកណា?** គោលដៅគឺសម្រាប់ខ្លួនអ្នក
- **អ្វី?** គឺជាអ្វីដែលអ្នកចង់សម្រេចបាន
- **នៅទីណា?** តើទីណាដែលអ្នកចង់ទៅដល់ដើម្បីសម្រេចគោលដៅនេះ?
- **ពេលណា?** នៅពេលណាដែលអ្នកសង្ឃឹមថាអ្នកអាចសម្រេចគោលដៅនេះបាន

២. ធាតុទាំង២ក្នុងការធ្វើផែនការដើម្បីសំរេចគោលដៅ

- ៤+១ "**ធ្វើដូចម្តេច?**" តើអ្នកអាចសម្រេចវាបានយ៉ាងដូចម្តេច?
  - **សកម្មភាព** ៖ តើសកម្មភាពអ្វីខ្លះដែលចាំបាច់សម្រាប់ឈានទៅដល់គោលដៅរបស់អ្នក?
  - **សេចក្តីត្រូវការ** ដើម្បីសម្រេចគោលដៅនេះ តើអ្នកត្រូវការអ្វីខ្លះ (ការអប់រំ បទពិសោធន៍ ធនធាន បណ្តាញគាំទ្រ)?
- ៤+២ "**ភាពអាចធ្វើបាន**" តើគោលដៅនេះមានភាពប្រាកដនិយម និងអាចសម្រេចទៅបានដែរឬទេ?

៣. យើងប្រើវិធីសាស្ត្រធ្វើផែនការដើម្បីសំរេចគោលដៅ ៤+២ ដើម្បីធ្វើផែនការឱ្យសម្រេចគោលដៅមុខរបររបស់យើង ។

យើងនឹងធ្វើការពិចារណាពីអ្វីដែលយើងបានគិត និង រៀនរយៈពេល ២-៣ សប្តាហ៍កន្លងមក និង ព្យាយាមកំណត់មុខរបរខ្លះ ដែលអាចសម្រេចបានដោយស្របជាមួយនឹងចំណាប់អារម្មណ៍ និងទេពកោសល្យរបស់យើង ។

## ការសម្រេចចិត្តលើការជ្រើសរើសមុខរបរ

១. ចូរជ្រើសរើសយកគំនិតមួយសម្រាប់ជម្រើសមុខរបរដែលមានសក្តានុពលដោយផ្អែកលើ :

- ការពិនិត្យឡើងវិញលើកដំបូងរបស់អ្នក ពីចំណាប់អារម្មណ៍ ទេពកោសល្យ និង ជំនាញ
- បទពិសោធន៍ធ្វើសម្ភាសរបស់អ្នក
- ចំណាប់អារម្មណ៍មុខរបរថ្មីដែលអ្នកបានរៀន ឬ បានគិតកាលពី ២-៣ សប្តាហ៍កន្លងមក ។

២. សរសេរពីជម្រើសមុខរបរដែលជាគោលដៅដែលអ្នកចង់ឱ្យសម្រេច ដោយរួមបញ្ចូលធាតុទាំង ៤ ។

| | | |
|---|---|---|
| o | **អ្នកណា?** | = |
| o | **អ្វី?** | = |
| o | **នៅទីណា?** | = |
| o | **ពេលណា?** | = |

## ការធ្វើផែនការដើម្បីសំរេចគោលដៅមុខរបរ ដោយប្រើវិធីសាស្ត្រ ៤+២

១. ប្រើប្រាស់គោលដៅមុខរបរដែលអ្នកទើបសរសេររួចតាមវិធីសាស្ត្រ ៤+១ "ធ្វើដូចម្តេច" ដោយចាប់ផ្តើមគិតពីសកម្មភាព និង សេចក្តីត្រូវការដើម្បីឈានទៅសម្រេចគោលដៅនោះ ។

**សកម្មភាព**

**តម្រូវការ**

២. ក្រោយពីបញ្ចប់កិច្ចការនេះ អ្នកត្រូវគិតថា "តើគោលដៅនេះអ្នកអាចធ្វើបាន ឬ អាចសម្រេចបាន និងមានលក្ខណៈប្រាកដជាក់លាក់ដែរឬទេ?" **បាន ឬ មិនបាន**

៣. ប្រសិនបើចម្លើយ **ទេ** សូមពិនិត្យមើលគោលដៅ និង ចម្លើយចំពោះសំណួរ "ធ្វើដូចម្តេច? " ធ្វើដូចនេះចម្លើយរបស់អ្នកសម្រាប់៤+២ គឺ **បាន**។

៤. ចូរដាក់ឈ្មោះសកម្មភាពដែលអ្នកអាចចាប់ផ្តើមដើម្បីឈានទៅសម្រេចគោលដៅរបស់អ្នក។

**ការពិភាក្សាពីការប្រឈមចំពោះគោលដៅ និង ការធ្វើផែនការ**

១. តើបញ្ហាប្រឈមអ្វីខ្លះដែលអ្នកបានជួបប្រទះក្នុងការធ្វើផែនការគោលដៅមុខរបរដោយប្រើ វិធីសាស្ត្រ ៤ +២?

២. ដើម្បីគិតពីគោលដៅមុខរបររបស់អ្នក ចូរអ្នកកំណត់បញ្ហាប្រឈមដែលអ្នកអាចជួបប្រទះក្នុងដំណើរឆ្ពោះទៅរកគោលដៅនេះ?

# មេរៀនទី៧ : ការធ្វើសេចក្ដីសម្រេចចិត្ត

## ☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កំណត់ដំណាក់កាលនៃដំណើរការការធ្វើការសម្រេចចិត្ត
- កំណត់កត្តាដែលជះឥទ្ធិពលលើដំណើរការការសម្រេចចិត្ត និងផលវិបាកក្នុងការធ្វើការសម្រេចចិត្ត
- កំណត់វិធីឈានទៅរកមុខរបរ និងធ្វើផែនទីបង្ហាញផ្លូវតាមផែនការឆ្ពោះទៅរកមុខរបរនោះ ។

## ការណែនាំពីការធ្វើសេចក្ដីសម្រេចចិត្ត

នៅលើដំណើរផ្លូវឆ្ពោះទៅរកការសម្រេចគោលដៅវាតែងមានឧបសគ្គ និង បញ្ហាប្រឈមជាច្រើនកើតឡើង ។ វាជាការសំខាន់សម្រាប់សិស្សធ្វើការពង្រឹងជំនាញក្នុងការសម្រេចចិត្តប្រកបដោយភាពវៃឆ្លាត និងឆ្ពោះទៅរកគោលដៅ

- ការសម្រេចចិត្តមួយចំនួនមានភាពងាយស្រួល ។ ឧទាហរណ៍ តើយើងត្រូវជ្រើសរើសយកមុខម្ហូបមួយណាសម្រាប់អាហារពេលព្រឹក?
- ការសម្រេចចិត្តខ្លះមិនមានភាពងាយស្រួលនោះទេ ។ ឧទាហរណ៍ តើយើងត្រូវនៅផ្ទះដើម្បីមើលសាច់ញាតិដែលមានជំងឺ ឬ យើងត្រូវទៅសាលារៀន?

១. ចូរអ្នកផ្ដល់ឧទាហរណ៍មួយស្ដីពីការសម្រេចចិត្តដែលមានភាពងាយស្រួល ។

______________________________

______________________________

______________________________

២. ចូរអ្នកផ្ដល់ឧទាហរណ៍មួយស្ដីពីការសម្រេចចិត្តដែលមិនមានភាពងាយស្រួល ។

______________________________

______________________________

______________________________

## លំនាំធ្វើសេចក្តីសម្រេចចិត្ត

មានជំហាន ៥ ដែលយើងត្រូវអនុវត្តសម្រាប់ធ្វើការសេចក្តីសម្រេចចិត្ត ៖

១. កំណត់បញ្ហា

២. ប្រមូលព័ត៌មាន ពិចារណាលើដំណោះស្រាយ

៣. ធ្វើបញ្ជីពីការសម្រេចចិត្តមួយចំនួន

៤. ពិចារណាលើផលវិបាកនៃការសម្រេចចិត្តមួយចំនួន

៥. ជ្រើសរើសវិធីធ្វើការសម្រេចចិត្តល្អបំផុត

## យុទ្ធវិធីធ្វើការសម្រេចចិត្ត ឬ លក្ខណៈសម្គាល់

នៅពេលយើងធ្វើការសម្រេចចិត្តធម្មតា យើងមានគំនិតច្រើន។ នៅពេលយើងធ្វើការសម្រេចចិត្ត តម្លៃរបស់យើង ដៃគូ ទម្លាប់ អារម្មណ៍ គ្រួសារ ការប្រថុយ និង ផលវិបាក រយៈពេល អាយុ និង រឿងរ៉ាវជាច្រើនទៀតអាចមានឥទ្ធិពលលើការសម្រេចចិត្តដែលយើងត្រូវធ្វើ។

១. នេះជាយុទ្ធវិធីនៃការធ្វើការសម្រេចចិត្តមួយចំនួន។

- ការធ្វើឡើងដោយឯងៗ (ការជ្រើសរើសដោយមិនបានគិត កើតឡើងភ្លាមៗដោយមិនមានជម្រើសពិចារណាផ្សេងៗ)
- ភាពស្របគ្នា (ផ្តល់ឱ្យមានការសង្ឃឹមទុក ឬមានសម្ពាធពីអ្នកផ្សេង)
- ការពន្យារពេល (ពន្យារពេលពីមួយថ្ងៃទៅមួយថ្ងៃរហូតដល់ការជ្រើសរើសកាន់តែមានកម្រិតទាប)
- ចេតនាចង់បាន (មានចំណង់ខ្លាំង ដោយមិនបានគិតពីផលវិបាក ឬ តម្លៃ)
- ការគេចវេះ (ការជៀសពីការលំបាក ការមិនចូលចិត្ត ឬ ភាពមិនសមគួរ)
- សន្តិសុខ (ការសម្រេចចិត្តដែលមានសុវត្ថិភាព មានការប្រថុយតិច ឬ ផលវិបាកតិច )
- បំណងប្រាថ្នា (ស្របជាមួយគោលបំណង និង គោលដៅ)
- ភាពសមហេតុផល (ដោយធ្វើការថ្លឹងថ្លែងពីការគាំទ្រ និង ប្រឆាំង)
- ភាពងាយស្រួល (ជម្រើសដែលមើលទៅហាក់ដូចជាងាយស្រួលបំផុត)

# សៀវភៅសិស្ស

២. ចូរជ្រើសរើសយុទ្ធវិធីចំនួន ៣ ដែលមានរៀបរាប់ខាងលើ ហើយសរសេរឧទាហរណ៍មួយសម្រាប់យុទ្ធវិធីនីមួយៗដែលយុទ្ធវិធីទាំងនោះអាចយកទៅអនុវត្តក្នុងស្ថានភាពណាមួយ ។

**ឧទាហរណ៍**

ឈ្មោះយុទ្ធវិធីការធ្វើឡើងដោយឯងៗ

ខ្ញុំហួសម៉ោងទៅសាលា ដូចនេះខ្ញុំរត់ទៅសាលានៅពេលខ្ញុំចប់ការងារជួយលក់ដូរម្តាយរបស់ខ្ញុំ ។ ដោយប្រញាប់ពេកខ្ញុំបានសម្រេចទិញទំនិញពីអ្នកលក់នៅក្បែរ នោះដើម្បីសន្សំពេលវេលាជាជាងដើរទៅទិញនៅកន្លែងដែលខ្ញុំធ្លាប់ទៅ ។

ឈ្មោះយុទ្ធវិធី

ឧទាហរណ៍

ឈ្មោះយុទ្ធវិធី

ឧទាហរណ៍

ឈ្មោះយុទ្ធវិធី

ឧទាហរណ៍

៣. តើយុទ្ធវិធីទាំងអស់វាអាចប្រើប្រាស់បានឬទេ? ហេតុអ្វី?

៤. តើយុទ្ធវិធីណាមួយដែលអ្នកគិតថាល្អប្រសើរបំផុត ដើម្បីប្រើក្នុងការសម្រេចចិត្តរយៈពេលយូរ?

៥. តើមានកត្តាសេដ្ឋកិច្ចអ្វីខ្លះដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នក?

## ករណីសិក្សារបស់ថានីស្តីពីការសម្រេចចិត្ត

ថានីបានរៀនចប់ថ្នាក់ទី ៨។ គេជាសិស្សល្អម្នាក់ ដែលមានការសប្បាយនឹងការសិក្សា ពីអ្វីថ្មីៗ និង ជួយមិត្ត។ គ្រួសារថានីមានការលំបាកព្រោះគ្រួសារគេមានភាពក្រីក្រ។ ពួកគេមិនមានប្រាក់ច្រើនសម្រាប់ផ្តល់ឱ្យបងប្រុសរបស់គេរៀបការទេ។ ថានីមានជំនាញដូចជា ធ្វើគ្រឿងអលង្ការ និងជួសជុលម៉ូតូ។ គ្រួសារថានីគិតថា គេគួរតែឈប់រៀនដើម្បីធ្វើការពេញម៉ោងសម្រាប់រកប្រាក់មកឱ្យគ្រួសារ។

ជីវិតរបស់គេកាន់តែមានការលំបាកទៅៗ និងកាន់តែលែងមានភាពសប្បាយរីករាយ ដោយសារតែមានការខ្វះខាត ដូចនេះគេត្រូវតែធ្វើការសម្រេចចិត្តធ្វើអ្វីមួយ។

១. ត្រូវចងចាំពីលំនាំនៃការធ្វើសេចក្ដីសម្រេចចិត្ត ៖

- ការកំណត់បញ្ហា
- ការប្រមូលព័ត៌មាន ពិចារណាលើដំណោះស្រាយ និង ធ្វើបញ្ជីការសម្រេចចិត្តផ្សេងៗ
- ការពិចារណាលើផលវិបាកពីការសម្រេចចិត្តផ្សេងៗ
- ការជ្រើសរើសវិធីធ្វើការសម្រេចចិត្តល្អបំផុត

២. តើបញ្ហារបស់ថានីជាអ្វី?

- ថានីចង់នៅរៀនបន្ត ប៉ុន្តែគ្រួសាររបស់គេដាក់សម្ពាធលើគេឱ្យបោះបង់ការសិក្សា ដើម្បីទៅធ្វើការ ។

៣. តើមានមធ្យោបាយអ្វីខ្លះដែលអាចធ្វើឱ្យថានីស្វែងរកបានព័ត៌មានច្រើន ដើម្បីជួយឱ្យថានីមានដំណោះស្រាយសម្រាប់បញ្ហានេះ?

- ថានីទៅកន្លែងធ្វើគ្រឿងអលង្ការក្នុងមូលដ្ឋាន និងកន្លែងជួសជុលម៉ូតូ ដើម្បីស្វែងរកជម្រើសផ្សេងៗសម្រាប់រូបគាត់ ពីរឿងធ្វើការពាក់កណ្ដាលម៉ោង ឬ ពេញម៉ោង ដើម្បីទទួលប្រាក់កំរៃតាមម៉ោង ឬ តាមសប្ដាហ៍ ឬ ការបត់បែននៃពេលវេលាតាមកាលវិភាគរបស់គាត់ (ដើម្បីដោះស្រាយតម្រូវការម៉ោងសិក្សានៅសាលា) ។
- ថានីត្រូវធ្វើការស្វែងយល់ពីជម្រើសផ្សេងទៀត ដែលសមាជិកគ្រួសារអាចរកប្រាក់ចំណូល ។

៤. តើមានដំណោះស្រាយផ្សេងទៀត និងការលំបាកអ្វីខ្លះសម្រាប់ថានី?

<table>
<tr><th colspan="2">ដំណោះស្រាយ និង ផលវិបាក</th></tr>
<tr><th>វិជ្ជមាន</th><th>អវិជ្ជមាន</th></tr>
<tr><td colspan="2">ដំណោះស្រាយ ១: ថានី អាចបោះបង់ការសិក្សា ព្រោះគ្រួសារគេចង់ឱ្យគេធ្វើជាអ្នកធ្វើគ្រឿងអលង្ការផង និង ធ្វើជាជាងម៉ូតូផង ។</td></tr>
<tr><td>○ ជម្រើសអនាគតកាន់តែមានកម្រិត ប៉ុន្តែគេអាចទទួលបានការហ្វឹកហ្វឺន និងបទពិសោធក្នុងការធ្វើគ្រឿងអលង្ការ និង ជួសជុលម៉ូតូ ។<br>○ គេអាចរកប្រាក់ចំណូល ប៉ុន្តែវាមិនមែនអស្ចារ្យនោះទេ ។<br>○ គ្រួសារគេនឹងសប្បាយរីករាយ ។</td><td>○ បោះបង់ការសិក្សានៅត្រឹមថ្នាកទី ៨ គឺ ( គ្មានលទ្ធភាពក្នុងការចូលរៀនវិញ)<br>○ គេអាចបោះបង់ឱកាសមុខរបរ វិជ្ជាជីវៈដែលធ្វើ ឱ្យគេទទួលប្រាក់ច្រើននាពេលអនាគត ។<br>○ គេនឹងមិនសប្បាយចិត្ត ។<br>○ គេនឹងនឹកមិត្តរួមថ្នាក់របស់គេ ព្រមទាំងលែងបានជួបពួកគេជារៀងរហូត ។</td></tr>
<tr><td colspan="2">ដំណោះស្រាយ ២ : ថានី អាចទៅរៀនបាន ប៉ុន្តែគេត្រូវធ្វើការក្រៅម៉ោង ។</td></tr>
<tr><td>○ គេមានឱកាសអាចទៅរៀនបន្តនៅវិទ្យាល័យ និង ត្រៀមប្រឡងបញ្ចប់វិទ្យាល័យដែលជាសញ្ញាប័ត្រដ៏មានសារប្រយោជន៍ ។<br>○ គេមានការសប្បាយក្នុងការបន្តការសិក្សា ។<br>○ គេនឹងទទួលបានប្រាក់ចំណូលខ្លះៗសម្រាប់គ្រួសារ ។<br>○ គ្រួសាររបស់គេមិនសប្បាយចិត្ត ។</td><td>○ គេនឹងមិនអាចទទួលប្រាក់ច្រើន សម្រាប់គ្រួសារដូចការធ្វើការងារពេញម៉ោងនោះទេ ។<br>○ គេនឹងមានការហត់នឿយពីការធ្វើការផង និងរៀនផង ។<br>○ គ្រួសាគេមិនពេញចិត្តទាំងស្រុងនោះទេ ។<br>○ បងប្រុសរបសគេគ្មានប្រាក់ដើម្បីរៀបការ ។<br>○ គេមានពេលតិចតួចសម្រាប់ការកំសាន្ត និងការនៅជាមួយមិត្តភក្តិ ។</td></tr>
<tr><td colspan="2">ដំណោះស្រាយ ៣ : ថានី អាចធ្វើការងារទាំង ២ បាននៅក្នុងពេលវិស្សមកាល</td></tr>
<tr><td>○ គេអាចទទួលបានបទពិសោធន៍ និងការហ្វឹកហ្វឺន ។<br>○ គេនឹងទទួលប្រាក់ចំណូល ២កន្លែង ដែលគេអាចរួមចំណែកក្នុងការរៀបអាពាហ៍ពិពាហ៍បងប្រុសរបស់គេ ។<br>○ គេមិនគួរមានការបង្អាក់ក្នុងការទៅសាលា ហើយគួរតែធ្វើផែនការដោយផ្តោតលើការសិក្សា ។<br>○ គេនឹងមានពេលសិក្សា និងមានពេលនៅជាមួយមិត្តភក្តិរបស់គេ ។</td><td>○ ថានីធ្វើការនៅពេលវិស្សមកាល មិនអាចមានប្រាក់គ្រប់គ្រាន់សម្រាប់គ្រួសារ ដើម្បីឱ្យមានស្ថេរភាព យូរបានទេ ។<br>○ សម្ពាធពីគ្រួសារនឹងកើនឡើងពេញមួយវិស្សមកាល ធ្វើឱ្យគេមិនអាចឈប់ពីការងារ ហើយគេប្រឈមនឹងបញ្ហាដូចគ្នាជាថ្មីពីការសិក្សា និងការងារ ។<br>○ គេមិនអាចរកប្រាក់បានច្រើនសម្រាប់ជួយរៀបការបង ។</td></tr>
<tr><td colspan="2">ដំណោះស្រាយ ៤ : ថានី អាចធ្វើព្រងើយកន្តើយនឹងគ្រួសាររបស់គេ ដោយសម្រេចបន្តការសិក្សា ហើយមិនទៅធ្វើការ</td></tr>
<tr><td>○ គេសប្បាយចិត្តព្រោះគេផ្តោតទៅលើតែការសិក្សាមួយមុខប៉ុណ្ណោះ ។<br>○គេមានពេលវេលាច្រើនធ្វើកិច្ចការសាលា ។<br>○គេមានពេលសប្បាយរីករាយច្រើន ជាមួយមិត្តភក្តិ ។<br>○គេផ្តោតតែទៅលើសក្តានុពល អនាគតរបស់គេ ។</td><td>○ គ្រួសារគេនឹងខឹងជាមួយគេ ។<br>○ គេនឹងបណ្តេញចេញពីផ្ទះព្រោះគេយល់ថាការសិក្សាមិនមានសារៈសំខាន់ដូចធ្វើការនោះទេ ។<br>○ គេនឹងមិនមានការគាំទ្រសម្រាប់បន្តការសិក្សាតទៅមុខទៀត ។<br>○ គេមិនអាចអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់គេដែលអាចជួយឱ្យគេរកប្រាក់ចំណូលសម្រាប់ការរស់នៅរបស់គេនាពេលអនាគត ។</td></tr>
</table>

៥. តើអ្នកគិតថាមធ្យោបាយអ្វីដែលល្អបំផុតសម្រាប់ថានី? ចូរបង្ហាញពីហេតុផលរបស់អ្នកដែលគិតឃើញបែបនេះ ។

## ការបង្កើតករណីសិក្សាស្តីពីការធ្វើសេចក្តីសម្រេចចិត្ត

១. ចូរអ្នកបង្កើតករណីសិក្សាផ្ទាល់ខ្លួនរបស់អ្នកស្តីពីការធ្វើសេចក្តីសម្រេចចិត្ត ។

២. ចូរកំណត់បញ្ហាដែលមានការលំបាកក្នុងការដោះស្រាយនៅក្នុងករណីសិក្សារបស់អ្នក ។

- អាចជាបញ្ហាដែលអ្នកធ្លាប់ជួបប្រទះ
- អាចជាបញ្ហាដែលជួបប្រទះដោយមនុស្សណាម្នាក់ដែលអ្នកស្គាល់
- ជាបញ្ហាដែលអ្នកបានបង្កើតឡើងតាមការនឹកឃើញ

ការកំណត់

៣. ចូរបង្កើតតួអង្គម្នាក់ និង ឈុតមួយដើម្បីបង្ហាញឱ្យឃើញពីបញ្ហានេះ ដូចដែលបានកើតមានក្នុងករណីសិក្សារបស់ថានី ។ (ប្រើសៀវភៅកត់ត្រាមេរៀនរបស់អ្នកប្រសិនបើអ្នកត្រូវការសរសេរបន្ថែមទៀត) ។

៤. ចូរបង្កើតតារាងដំណោះស្រាយផ្សេងៗចំពោះផលវិបាកដែលបានកំណត់ឃើញ។ (ប្រើសៀវភៅកត់ត្រាមេរៀនរបស់អ្នក ប្រសិនបើអ្នកត្រូវការសរសេរបន្ថែមទៀត។)

| ដំណោះស្រាយ និង ផលវិបាក | |
|---|---|
| **វិជ្ជមាន** | **អវិជ្ជមាន** |
| **ដំណោះស្រាយ ១** | |
| | |
| **ដំណោះស្រាយ ២** | |
| | |
| **ដំណោះស្រាយ ៣** | |
| | |
| **ដំណោះស្រាយ ៤** | |
| | |

៥. តើមានជម្រើសណាមួយដែលអ្នកគិតថាជាដំណោះស្រាយល្អបំផុតសម្រាប់ករណីសិក្សារបស់អ្នក? ចូរពន្យល់។

## មេរៀនទី៨ : អ្នកធ្វើការសម្រេចចិត្តដែលឈ្លាសវៃ

### ☼ លទ្ធផលសិក្សារំពឹងទុក

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ប្រើប្រាស់លំនាំនៃការសម្រេចចិត្ត ដើម្បីកំណត់ជម្រើសផ្សេងៗ និង ការសម្រេចធ្វើសកម្មភាព
- បង្កើត និង វិភាគពីគោលការណ៍នៃការធ្វើសេចក្ដីសម្រេចចិត្ត ។

### ការពិភាក្សាពីអ្នកធ្វើសេចក្ដីសម្រេចចិត្តដែលឈ្លាសវៃ

ក្នុងការពិនិត្យលើករណីសិក្សារបស់ ថានី និងការណីសិក្សាមួយចំនួនទៀតដែលអ្នក និងសិស្សដទៃទៀតបានបង្កើត ចូរឆ្លើយនឹងសំណួរ ២ ខាងក្រោម :

១. តើមានដំណោះស្រាយណាមួយដែលអ្នកមិនយល់ស្របតាមគំនិតដែលក្រុមរបស់អ្នកបានជ្រើសរើស? ចូរពន្យល់ ។

______________________________

______________________________

______________________________

______________________________

______________________________

២. តើមានលក្ខណៈសម្គាល់ និង សកម្មភាពអ្វីខ្លះដែលបញ្ជាក់ពីអ្នកធ្វើការសម្រេចចិត្តដែលឈ្លាសវៃ?

______________________________

______________________________

______________________________

______________________________

## ការសង្ខេបខ្លឹមសារឯកសារស្តីពីអនាគតខ្ញុំ

១. តើគោលដៅគឺជាអ្វី? ហេតុអ្វីបានជាគោលដៅមានសារៈសំខាន់?

________________________________________

________________________________________

________________________________________

________________________________________

២. តើមុខរបរអ្វី ដែលអ្នកមានការចាប់អារម្មណ៍បំផុត? ហេតុអ្វី?

________________________________________

________________________________________

________________________________________

________________________________________

៣. តើសេចក្តីត្រូវការអ្វីខ្លះ ដែលអ្នកត្រូវការដើម្បីឈានទៅសម្រេចមុខរបរនេះ? (សំណួរទី ២)

________________________________________

________________________________________

________________________________________

________________________________________

៤. តើមានមុខរបរអ្វីដែលអ្នកចង់ដឹងបន្ថែមទៀត? តើអ្នកអាចស្វែងរកព័ត៌មានទាំងនោះដោយរបៀបណា?

________________________________________

________________________________________

________________________________________

________________________________________

៥. តើគោលដៅសំខាន់បំផុតដែលអ្នកបានកំណត់សម្រាប់ខ្លួនអ្នកជាអ្វី?

---

---

---

៦. កំណត់ធាតុទាំង ៤ នៃគោលដៅរបស់អ្នកដែលអ្នកបានសរសេរខាងលើ ។

o **អ្នកណា?** =

o **អ្វី?** =

o **នៅទីណា?** =

o **ពេលណា?** =

៧. ក្រោយពីអ្នកសរសេរពីខ្លឹមសារគោលដៅរបស់អ្នក តើអ្វីទៅជាផែនការសកម្មភាពគោលដៅ ដែលអ្នកត្រូវធ្វើ?

៨. តើឧបសគ្គអ្វីខ្លះដែលអ្នកមានអារម្មណ៍ថា យើងអាចជួបប្រទះនៅពេលដែលគេព្យាយាម កំណត់ និង សម្រេចគោលដៅរបស់គេ?

៩. តើដំណាក់កាលអ្វីខ្លះក្នុងលំនាំនៃការធ្វើការសម្រេចចិត្តដែលអ្នកត្រូវធ្វើតាមដើម្បីដោះស្រាយបញ្ហាប្រឈម និង ធ្វើការជ្រើសរើស?

១០. ផ្អែកលើយុទ្ធវិធី និង លក្ខណៈសម្គាល់ទូទៅដែលបានប្រើប្រាស់សម្រាប់ធ្វើការសម្រេចចិត្ត និងបានពិភាក្សានៅក្នុងថ្នាក់ តើយុទ្ធវិធីមួយណា ដែលអ្នកបានប្រើប្រាស់ក្នុងរយៈពេលកន្លងមក? សូមលើកឧទាហរណ៍បញ្ជាក់ ។

១១. តើយុទ្ធវិធីណាមួយដែលអ្នកសង្ឃឹមថា និងប្រើប្រាស់វាច្រើននាពេលអនាគត? ហេតុអ្វី?

១២. តើអ្វីដែលជាចំណុចសំខាន់បំផុតដែលអ្នកបានរៀននៅក្នុងវគ្គសិក្សានេះ?

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូប្រើ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ........................ សាលា..................... . ខេត្ត.............. ស្រុក................. ថ្នាក់ទី ........ ប្រធានបទ................

| ចំណុចត្រូវដាក់ពិន្ទុ | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ<br>បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | | |
| **សង្កេតឥរិយាបថសិស្ស** | | ពិន្ទុ (១-៧) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរជាមួយក្រុម | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផលនិងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ។ | | |
| ៣ | **ការសម្រេចចិត្ត និងទំនុកចិត្តលើខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ។ | | |
| ៤ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីបញ្ហានេះ និងយល់ពីមូលហេតុដែលសមាជិកក្រុមមានការលំបាកក្នុងការចូលរួម។ | | |
| ៥ | **ចរិត និងការបង្កើតថ្មី:** មានចិត្តអំណត់ និងអារម្មណ៍ល្អ និងមានគំនិតផ្ទាល់ខ្លួនច្រើន។ | | |
| | **សរុបការសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ<br>( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស<br>( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥0=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ :    តារាងបូកសរុបរង្វាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត .......................... ស្រុក .........................សាលា ............................... ថ្នាក់ទី .......... ប្រធានបទ ....................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព    ថ្ងៃទី ........... ខែ ............. ឆ្នាំ ...........

នាយកសាលា    ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

**ឧបសម្ព័ន្ធ ២ :** **ទម្រង់វាយតម្លៃគ្រូបង្រៀនបំណិនជីវិត**

ខេត្ត/ក្រុង ............................ ស្រុក/ខណ្ឌ ....................................... ឃុំ/សង្កាត់ .......................................

កម្រងសាលារៀន ............................ សាលារៀន ................................ ឈ្មោះគ្រូ ................................... ភេទ ........

ថ្នាក់ទី ............... ប្រធានបទ ..................................................................... មេរៀន ...................................

ចំនួនសិស្សវត្តមាន ................. ស្រី ............. កាលបរិច្ឆេទវាយតម្លៃ : ថ្ងៃទី ............ ខែ ............... ឆ្នាំ .............

| **ខ្លឹមសារ** | **ពិពណ៌នាសកម្មភាព** | **ភស្តុតាងផ្សេងៗ** |
|---|---|---|
| **I- បន្ទប់រៀន :** ការរៀបចំតុបតែង-រដ្ឋបាលថ្នាក់របស់គ្រូ | | |
| **១.១.ការតុបតែង និង ដាក់តាំងសម្ភារៈ**<br><br>**លទ្ធផល**<br><br>☐ | ☐ មានរៀបចំតុបតែង បាវចនាជាតិ ព្រះឆាយាលក្ខ័ណ៍ និង ពាក្យស្លោកអប់រំ | |
| | ☐ មានតារាងផ្សេងៗ និង មានខ្លឹមសារបិទតាំងយ៉ាងត្រឹមត្រូវ | |
| | ☐ មានរូបភាព ផ្ទាំងសំណេរដាក់តាំងត្រឹមត្រូវតាមកំពស់សិស្ស | |
| | ☐ មានរូបភាពតាមមុខវិជ្ជា និង សម្ភារឧបទេសដាក់តាំងតាមជញ្ជាំង តាមកៀនសិក្សាតាមមុខវិជ្ជាងាយស្រួលយកមកប្រើ | |
| | ☐ មានដាក់តាំងបង្ហាញស្នាដៃសិស្ស (រូបភាព កិច្ចការ ឧបករណ៍...) | |
| **១.២.ការរៀបចំបង្គុយសិស្ស និងក្ដារខៀន**<br><br>**លទ្ធផល**<br><br>☐ | ☐ គ្រូបានរៀបចំបង្គុយសិស្សស្របតាមខ្លឹមសារមេរៀន និងសកម្មភាពរៀន និងបង្រៀន | |
| | ☐ តុសិស្សមានចំនួនសមស្របទៅនឹងចំនួនសិស្ស | |
| | ☐ តុសិស្សទាំងអស់ត្រូវបានថែទាំ និងរៀបចំដោយមានរបៀបរៀបរយល្អ | |
| | ☐ តុសិស្សមានកំពស់សមស្របតាមវ័យរបស់សិស្ស | |
| | ☐ បន្ទប់រៀនត្រូវបានសំអាតជាប្រចាំ និង គ្មានសង្ហារឹមបាក់បែក ក្នុងបន្ទប់ | |
| | ☐ មានក្ដារខៀន ធំ-តូច សម្រាប់ប្រើប្រាស់ក្នុងសកម្មភាពរៀន និង បង្រៀន | |
| **១.៣.ការងាររដ្ឋបាលរបស់គ្រូ**<br><br>**លទ្ធផល**<br><br>☐ | ☐ គ្រូបានស្រង់វត្តមានសិស្សជាប្រចាំ ហើយបញ្ជាក់មូលហេតុច្បាស់លាស់ ដោយមានចុះទិដ្ឋាការនាយកសាលា | |
| | ☐ គ្រូបានចុះពិន្ទុសិស្សរៀនបំណិនជីវិតគ្រប់ចំនួន និងបូកស្រង់ យ៉ាងត្រឹមត្រូវ ព្រមទាំងមានទិដ្ឋាការរបស់នាយក | |
| | ☐ គ្រូបានបំពេញសៀវភៅតាមដានការសិក្សារបស់សិស្ស យ៉ាងត្រឹមត្រូវ និង បញ្ជូនទៅមាតាបិតាសិស្សយ៉ាងទៀងទាត់រៀងរាល់ខែ | |
| | ☐ គ្រូបានប្រើប្រាស់សៀវភៅទំនាក់ទំនងចំពោះសិស្សដែលមានបញ្ហា (ឈប់ច្រើន គេចសាលា ...) ជាមួយមាតាបិតាសិស្សជាប្រចាំ | |
| | ☐ គ្រូបានកត់ខ្លឹមសារសំខាន់ៗ នៅក្នុងសៀវភៅផ្សេងៗ ដើម្បីយកទៅអនុវត្ត ក្រោយពេលប្រជុំ ការណែនាំ ការចូលរួម ... | |
| | ☐ គ្រូបានថែទាំ ទុកដាក់ឯកសារបំណិនជីវិត (ផ្លូវ៉ស្ទ័រគ្រូ ផូស្ទ័រសិស្ស ស្នាដៃសិស្ស ឯកសារសិស្ស)ព័ត៌មានរបស់សិស្ស និងឯកសារផ្សេងៗបានល្អ | |
| **II- ការបង្រៀន និង រៀន** | | |
| **២.១.ការរៀបចំកិច្ចតែង ការបង្រៀន**<br><br>**លទ្ធផល**<br><br>☐ | ☐ គ្រូបង្រៀនបានរៀបចំកិច្ចតែងការបង្រៀនជាប្រចាំ | |
| | ☐ កិច្ចតែងការបង្រៀន មានការកំណត់វត្ថុបំណងច្បាស់លាស់ស្របតាមខ្លឹមសារមេរៀន | |
| | ☐ សកម្មភាពក្នុងកិច្ចតែងការបង្រៀន ឆ្លើយតបទៅនឹងវត្ថុបំណងនៃមេរៀន | |
| | ☐ កិច្ចតែងការបង្រៀនមានលក្ខណៈពេញលេញ (ខ្លឹមសារ-សកម្មភាពគ្រូ -សកម្មភាពសិស្ស ) | |
| | ☐ កិច្ចតែងការបង្រៀន មានចុះទិដ្ឋាការរបស់នាយក | |

| | | |
|---|---|---|
| | ☐ កិច្ចតែងការមានខ្លឹមសារស្វ័យវាយតម្លៃរបស់គ្រូ | |
| **២.២.ការអនុវត្តកិច្ចតែងការបង្រៀន** | ☐ គ្រូបានប្រើប្រាស់កិច្ចតែងការបង្រៀន គ្រប់សកម្មភាពក្នុងម៉ោងសិក្សា | |
| | ☐ គ្រូបានប្រើប្រាស់ពេលវេលា សមស្របតាមជំហាននីមួយៗ | |
| **លទ្ធផល** | ☐ គ្រូបានអនុវត្តការងារតាមលំនាំសកម្មភាពច្បាស់លាស់ ( ក្រុមតូច ក្រុមធំ ) | |
| ☐ | ☐ គ្រូបានប្រើប្រាស់សកម្មភាពក្នុងកិច្ចតែងការបង្រៀន ដោយផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ និង ស្ថានភាពជាក់ស្តែងថែមទៀត | |
| | ☐ គ្រូបានព្យាយាមកែលំអ សកម្មភាពដឹកនាំឱ្យបានកាន់តែប្រសើរ ចំពោះសកម្មភាពណាដែលមិនសូវច្បាស់លាស់ | |
| | ☐ គ្រូបានធ្វើស្វ័យវាយតម្លៃលើកិច្ចតែងការបង្រៀន | |
| **២.៣.ការចាត់តាំងសកម្មភាពរៀន និង បង្រៀន** | ☐ គ្រូបានចាត់តាំងសកម្មភាពសិស្ស-ក្រុមសិស្ស ក្នុងថ្នាក់ ក្រៅថ្នាក់ តម្រូវតាមខ្លឹមសារមេរៀន | |
| | ☐ គ្រូបានរៀបចំសកម្មភាពសិស្សដោយចម្រុះភេទ និង សមត្ថភាព | |
| **លទ្ធផល** | ☐ គ្រូបានណែនាំសិស្ស និងក្រុមសិស្សបានច្បាស់លាស់រាល់ ពេលមុនធ្វើសកម្មភាព | |
| ☐ | ☐ សមាជិកក្នុងក្រុមនីមួយៗបានចូលរួមយ៉ាងសកម្ម និងមានការទទួលខុសត្រូវ( សួរសំណួរ-ផ្តល់យោបល់-បកស្រាយ-រាយការណ៍-កត់ត្រា ... ) | |
| | ☐ សកម្មភាពអនុវត្តរបស់សិស្ស ឆ្លើយតបទៅនឹងវត្ថុបំណងរបស់មេរៀន | |
| **២.៤.ការប្រើប្រាស់សំណួរ** | ☐ គ្រូបានផ្តោតលើការប្រើប្រាស់សំណួរយល់ដឹង និង ពិចារណាហ្មត់ចត់លើរាល់ខ្លឹមសារនៃមេរៀន ដើម្បីអភិវឌ្ឍការគិតរបស់សិស្ស | |
| | ☐ គ្រប់សំណួររបស់គ្រូ ស្របតាមកម្រិតយល់ដឹងរបស់សិស្ស និង ខ្លឹមសារមេរៀន | |
| **លទ្ធផល** | ☐ គ្រូបានព្យាយាមប្រើប្រាស់សំណួរបន្ថែម ដើម្បីបំពេញ និងពង្រឹងការយល់ដឹងរបស់សិស្ស | |
| ☐ | ☐ គ្រូបានផ្តល់ឱកាសឱ្យសិស្ស ក្រុមសិស្សសួរគ្រូ( ពេលមិនយល់ ឬ មិនច្បាស់លាស់ ) | |
| | ☐ គ្រូបានផ្តល់ឱកាសឱ្យសិស្ស ក្រុមសិស្ស សាកសួរគ្នាទៅវិញ ទៅមក ដើម្បីបញ្ជាក់ភាពច្បាស់លាស់របស់គេ | |
| **២.៥.ការប្រើប្រាស់សម្ភារឧបទេសក្នុងការរៀន និងបង្រៀន** | ☐ គ្រូ និង សិស្សបានត្រៀមសម្ភារឧបទេសគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់តាមក្រុម និង តាមសកម្មភាព | |
| | ☐ គ្រូបានរៀបចំសម្ភារឧបទេស និងប្រើប្រាស់តាមលំដាប់លំដោយនៃខ្លឹមសារមេរៀន និងសកម្មភាព | |
| **លទ្ធផល** | ☐ គ្រូបានប្រើប្រាស់ធនធានសម្ភារៈក្នុងបន្ទប់រៀន ផ្សារភ្ជាប់ទៅនឹង ខ្លឹមសារមេរៀន | |
| ☐ | ☐ គ្រូបានប្រើប្រាស់សម្ភារៈច្នៃប្រឌិត និងធនធានងាយៗ សម្រាប់ការរៀន និងបង្រៀន | |
| | ☐ គ្រូបានឱ្យសិស្សប្រើប្រាស់សម្ភារឧបទេសដោយផ្ទាល់ និងណែនាំ ពីងាយទៅលំបាក | |
| **២.៦.ការប្រើប្រាស់ឯកសារសិស្ស ធូស្ស័រសិស្ស និងឯកសារផ្សេងៗ** | ☐ គ្រូបានឱ្យសិស្សប្រើប្រាស់ឯកសារសិស្ស ដើម្បីធ្វើការស្រាវជ្រាវ | |
| | ☐ សិស្សភាគច្រើនមានឯកសារប្រើប្រាស់ក្នុងម៉ោងសិក្សា | |
| | ☐ សិស្សបានថែទាំ និងប្រើប្រាស់ឯកសារបំណិនជីវិតយ៉ាងត្រឹមត្រូវតាមការណែនាំ | |
| **លទ្ធផល** | ☐ គ្រូ និង សិស្សបានប្រើប្រាស់ឯកសារផ្សេងៗ ដើម្បីស្រាវជ្រាវសម្រាប់បំពេញបន្ថែមក្នុងខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅបំណិនជីវិត | |
| ☐ | ☐ គ្រូបានដាក់កិច្ចការ ដើម្បីឱ្យសិស្សធ្វើការស្រាវជ្រាវ និងសិក្សាបន្ថែមនៅបណ្ណាល័យ ឬ នៅក្នុងសហគមន៍ | |

| | | |
|---|---|---|
| **២.៧.សកម្មភាពពង្រីកបន្ថែម និងការបញ្ជ្រាបមេរៀនទៅក្នុងមុខវិជ្ជាដទៃ**<br><br>**លទ្ធផល**<br>☐ | ☐ គ្រូបានរៀបចំសកម្មភាពផ្សេងៗ ( ល្បែងសិក្សា-ល្បែងដើរតួ-ចម្រៀង-លំហាត់ប្រាណ ... ) ដើម្បីពង្រីកបន្ថែមក្នុងមេរៀន | |
| | ☐ គ្រូបានចាត់តាំងឱ្យមានការពិសោធ ស្រាវជ្រាវ សង្កេត សម្ភាសន៍ ដើម្បីពង្រឹង និង អភិវឌ្ឍន៍សមត្ថភាពសិស្ស | |
| | ☐ គ្រូបានបញ្ជ្រាបខ្លឹមសារមេរៀន ដោយផ្សារភ្ជាប់ពីមុខវិជ្ជាមួយទៅមុខវិជ្ជាដទៃទៀត | |
| | ☐ គ្រូបានឱ្យសិស្សប្រមូលព័ត៌មានផ្សេងៗនៅខាងក្រៅ ដើម្បីតម្រូវទៅនឹងខ្លឹមសារមេរៀន ដែលមានក្នុងឯកសារបំណិនជីវិតរបស់សិស្ស | |
| | ☐ គ្រូបានបង្រៀនមេរៀន ដោយផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅរបស់សហគមន៍ និង មូលដ្ឋាន | |
| **២.៨.ការដាក់កិច្ចការ និងការជួយសិស្សរៀនយឺត**<br><br>**លទ្ធផល**<br>☐ | ☐ គ្រូបានដាក់កិច្ចការស្របតាមសមត្ថភាពសិស្ស ជាពិសេសសិស្សរៀនយឺត | |
| | ☐ គ្រូបានសិក្សាច្បាស់លាស់ នូវស្តង់ដាកម្មវិធីសិក្សា សម្រាប់ការដាក់កិច្ចការ ឬ ធ្វើតេស្ត សម្រាប់ដាក់ពិន្ទុប្រចាំខែ ឬ ឆមាស | |
| | ☐ គ្រូបានពិនិត្យ និងកែកិច្ចការសិស្សបានត្រឹមត្រូវ និងទៀងទាត់ | |
| | ☐ គ្រូបានព្យាយាមជួយសិស្សរៀនយឺត និងកែលំអរាល់ចំណុចខ្វះខាត | |
| | ☐ គ្រូបានរៀបចំសិស្សពូកែតាមមុខវិជ្ជា ដើម្បីជួយសិស្សរៀនយឺត | |
| **២.៩.បរិយាកាសថ្នាក់រៀន និងការលើកទឹកចិត្ត**<br><br>**លទ្ធផល**<br>☐ | ☐ គ្រូបានប្រើប្រាស់ភាសាទំនាក់ទំនងយ៉ាងទន់ភ្លន់ និង ស្និទ្ធស្នាល ចំពោះសិស្សគ្រប់រូបដោយមិនរើសអើង | |
| | ☐ គ្រូមិនស្តីបន្ទោស ឬ ធ្វើទណ្ឌកម្មសិស្ស និង ព្យាយាមកែលំអពេលសិស្សឆ្លើយខុស ឬ ធ្វើអ្វីមួយខុស | |
| | ☐ គ្រូព្យាយាមជម្រុញ និងលើកទឹកចិត្តសិស្សដែលបានបញ្ចេញ យោបល់ ឬ សាកសួរ ឬ ឆ្លើយត្រូវ ឬ ធ្វើកិច្ចការមួយបានល្អ និង យកចម្លើយល្អទាំងនោះសម្រាប់កសាងខ្លឹមសារមេរៀនសង្ខេប | |
| | ☐ គ្រូព្យាយាមមកក្បែរ ឬ សំដែងការយកចិត្តទុកដាក់គ្រប់ពេល ចំពោះសិស្សរៀនយឺត និង សិស្សដែលជួបការលំបាក | |
| | ☐ គ្រូបានយកចិត្តទុកដាក់អប់រំណែនាំសិស្សជាប្រចាំ ដើម្បីបំបាត់ ភាពរើសអើងក្នុងថ្នាក់រៀន( ការសើច-ការធ្វើកាយវិការចំអក-ការបន្តុះបង្អាប់-ការប្រមាថមើលងាយ-ការបង្កជម្លោះ ...) | |
| **២.១០.ការដាក់កិច្ចការផ្ទះ**<br><br>**លទ្ធផល**<br>☐ | ☐ គ្រូបានដាក់កិច្ចការឱ្យសិស្សធ្វើនៅផ្ទះ យ៉ាងទៀងទាត់ | |
| | ☐ ខ្លឹមសារនៃសំណួរ ឬ លំហាត់សមស្របទៅនឹងកម្រិតយល់ដឹងរបស់សិស្ស | |
| | ☐ សំណួរ និងលំហាត់មានលក្ខណៈពង្រឹងចំណេះដឹង និងការស្រាវជ្រាវបន្ថែមក្រៅម៉ោងសិក្សា | |
| | ☐ គ្រូបានត្រួតពិនិត្យ និង កែកិច្ចការផ្ទះរបស់សិស្សជាប្រចាំ | |
| | ☐ សិស្សម្នាក់ៗមានសៀវភៅកិច្ចការ និង បានប្រើប្រាស់-ថែទាំ យ៉ាងត្រឹមត្រូវ ។ | |

**ក្រុមពិនិត្យតាមដាន**

**យោបល់របស់គ្រូបង្រៀន**

.................................................................

.................................................................

.................................................................

ហត្ថលេខា

ឈ្មោះគ្រូបង្រៀន

១- លោក/លោកស្រី .............................. ហត្ថលេខា...........

២- លោក/លោកស្រី .............................. ហត្ថលេខា........... .

ពិន្ទុផ្នែកបន្ទប់រៀន : ..................../១៧

ពិន្ទុផ្នែកការបង្រៀន និងរៀន : ....................../៥២

ពិន្ទុសរុប : ............................/៦៩

# ស្ថានភាពគ្រោះថ្នាក់ និងគ្មានអនាម័យ



ធ្វើការជាមួយជាតិគីមី
គ្រោះថ្នាក់

ធ្វើការជាមួយ
ម៉ាស៊ីនគ្រោះថ្នាក់





បាញ់ថ្នាំ
សម្លាប់សត្វល្អិត



បន្ទប់ទឹកគ្មានអនាម័យ និងមិន
មានបង្គន់គ្រប់គ្រាន់សម្រាប់ស្ត្រី

ធ្វើការនៅកន្លែង
ដែលសម្លេងខ្លាំង





ធ្វើការនៅកន្លែងបិទជិត និងមិន
មានខ្យល់អាកាសល្អចេញចូល



ធ្វើការនៅក្នុងផ្ទះ
ដែលមានកន្លែង
អង្គុយមិនសមរម្យ



កុមារ និងមនុស្សវ័យជំទង់
ធ្វើការនៅកន្លែងនេសាទ
និងអណ្តូងរ៉ែ

កុមារធ្វើការ
ជាការបម្រើ
នៅតាមផ្ទះ



ក្រសួងកិច្ចការនារី

MINISTERIO
DE ASUNTOS EXTERIORES
Y DE COOPERACIÓN

aecid

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

giz
Deutsche Gesellschaft
für Internationale
Zusammenarbeit (GIZ) GmbH